# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាជំហានទីមួយនៅចំការឡើង
# ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨
*ធ្វើជាយ៉ូហានបាទីស្តដើម្បីបង្ហាញព្រះយេស៊ូ*

អត្ថបទទី១៖ អស ៤៩,១-៦
អត្ថបទទី២៖ កក ១៣,២២-២៦
ដំណឹងល្អ៖ លក ១,៥៧-៦៦.៨០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពថ្ងៃកំណើតសន្តយ៉ូហានបាទីស្ទ ជាបងជីដូនមួយរបស់ព្រះយេស៊ូ ជាកូនយាយអេលីសាប៉ែតនិងលោកសាហ្គារី។ លោកសាហ្គារី មិនជឿលើព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែលប្រទានឲ្យប្រពន្ធគាត់មានផ្ទៃពោះ ធ្វើឲ្យគាត់ក្លាយជាមនុស្សគរហូតដល់ថ្ងៃដែលយ៉ូហានបាទីស្ទបានកើត គាត់បានដាក់ឈ្មោះឲ្យកូនថាយ៉ូហានបាទីស្ទ រំភេចនោះគាត់អាចនិយាយបាន។ ដោយសារគាត់បានបង្ហាញថាគាត់ទុកចិត្តលើព្រះជាម្ចាស់ គាត់បាផ្ញើជីវិតទៅលើព្រះជាម្ចាស់ ប្រាំបួនខែដែលគាត់និយាយមិនបាន ជាពេលវេលាមួយដែលទទួលអាចទទួលស្គាល់ពិតមែនព្រះជាម្ចាស់ស្រឡាញ់គាត់ ពិតមែនព្រះជាម្ចាស់បានប្រទានការដូមួយយ៉ាងពិសេសដល់គ្រួសារគាត់។ **យ៉ូហាន** មានន័យថា ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណា **បាទីស្ទ** មានន័យថា ពិធីជ្រមុជទឹក។

តាមពិត យ៉ូហានបាទីស្ទ បានបង្ហាញអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ អំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដោយយកយាយអេលីសាប៉ែត និងលោកតាសាហ្គារី ធ្វើជាឪពុកម្ដាយរបស់ព្យាការីចុងក្រោយ។ តួនាទីរបស់ព្យាការី គឺថ្លែងដំណឹងល្អដើម្បីរៀបចំផ្លូវទទួលការសង្គ្រោះដ៏ពេញលក្ខណៈ។ ពីសម័យដើម គេទន្ទឹងរង់ចាំការសង្គ្រោះ គេបានស្ដាប់ព្យាការី យេរេមី អេសាយ អូសេ អម៉ូស... ប៉ុន្តែមិនទាន់មានព្រះសង្គ្រោះយាងមក។ តួនាទីរបស់យ៉ូហានបាទីស្ទ គឺចង្អុលបង្ហាញព្រះយេស៊ូ ធ្វើឲ្យទាំងអស់គ្នាមើលព្រះយេស៊ូ។ រាល់ថ្ងៃលោកបូជាចារ្យ បានចង្អុលព្រះយេស៊ូដើម្បីឲ្យបងប្អូនមើលឃើញព្រះយេស៊ូ។

ថ្ងៃនេះយើងសប្បាយចិត្ត ដោយសារមានបេក្ខជនដែលបានសុំយកព្រះគ្រីស្ត យកព្រះបន្ទូល យកព្រះសហគមន៍ ជាទីពឹង ដើម្បីធ្វើដំណើរតទៅមុខ។ យើងជាគ្រីស្តបរិស័ទ យើងបីដូចជាយ៉ូហានបាទីស្ត យើងបានសម្ដែងព្រះហឫទ័យមេត្តាករុណា សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះបងប្អូនឯទៀតៗ។ យើងធ្វើពិធីជ្រមុជទឹក ដើម្បីកែប្រែចិត្តគំនិតទៅជាមនុស្សថ្មី។ បងប្អូនដែលសុំធ្វើជំហានទីមួយ បានឆ្លើយយ៉ាងច្បាស់ថា យើងសុំចូលនៅក្នុងព្រះសហគមន៍ដើម្បីសុំជំនឿ ជំនឿណែនាំឲ្យយើងទទួលជីវិតអស់កល្បជានិច្ច។ ដើម្បីទទួលជីវិតអស់កល្បជានិច្ច ដូចយ៉ូហានបាទីស្តពីមួយថ្ងៃទៅមួយថ្ងៃ យើងត្រូវតែកែប្រែចិត្តគំនិតថែមទៀតដើម្បីរស់នៅតាមរបៀបព្រះយេស៊ូ។ អំបាញ់មិញយើងបានគូសសញ្ញាឈើឆ្កាង៖

**លើភ្នែក** ដោយសារយើងត្រូវការមើលឃើញបងប្អូនដែលកំពុងមានទុក្ខលំបាក ត្រូវការមើលរបៀបដែលព្រះយេស៊ូស្រឡាញ់ដើម្បីស្រឡាញ់ដូចព្រះយេស៊ូ។

**លើត្រចៀក** ដោយសារយើងត្រូវការបើកត្រចៀកយ៉ាងធំដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ និងដើម្បីស្ដាប់សេចក្ដីត្រូវការរបស់បងប្អូនឯទៀតៗ ឲ្យគេមានសេចក្ដីសុខ។

**លើមាត់** ដើម្បីបើកមាត់ប្រកាសដំណឹងល្អ ដើម្បីបង្ហាញចិត្តគំនិតរបស់យើង ដែលមានព្រះជាម្ចាស់និយាយតាមបបូរមាត់របស់យើង តាមវិញ្ញាណរបស់យើង។

**លើទ្រូង** ជាកន្លែងដែលយើងមានបេះដូង ដែលជាជីវិតរបស់យើង ជាកន្លែងដែលណែនាំឲ្យយើងពោរពេញដោយសេចក្ដីស្រឡាញ់ ជាចិត្តដែលណែនាំឲ្យយើងមានកម្លាំងដើម្បីទៅមុខ។ ពេលយើងគូសសញ្ញាឈើឆ្កាងលើទ្រូង ណែនាំឲ្យយើងនឹកឃើញព្រះជាម្ចាស់មានវត្តមាននៅក្នុងដួងចិត្តរបស់ខ្ញុំយ៉ាងពិតប្រាកដ ព្រះជាម្ចាស់មានវត្តមាននៅក្នុងជីវិតរបស់ខ្ញុំយ៉ាងពិតប្រាកដ។ ឲ្យយើងយកចិត្តទុកដាក់ជាមួយអ្នកដទៃ សុំឲ្យព្រះយេស៊ូគង់នៅជាមួយគេ ដើម្បីឲ្យគេមានសុភមង្គល។

**លើដៃ** ជាសញ្ញាសម្គាល់នៃកម្លាំងរបស់យើង ដើម្បីជួយគេ ដើម្បីលើកទឹកចិត្តគេ ដើម្បីផ្ដល់កម្លាំងឲ្យគេ។ នៅក្នុងព្រះសហគមន៍ យើងបានរកឃើញក្រុមគ្រួសារមួយយ៉ាងពិសេស ដែលបានផ្ដល់ភាពកក់ក្ដៅ លើកទឹកចិត្ត និងណែនាំឲ្យយើងធ្វើដំណើរជាមួយគ្នានៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដោយសារយើងចេះយកចិត្តទុកដាក់។

សូមព្រះជាម្ចាស់ប្រទានពរ ដល់បងប្អូនទាំងអស់ ជាពិសេសព្រះសហគមន៍ថ្មីៗ ឲ្យមានកម្លាំងដើម្បីផ្ដល់សក្ខីភាព៕ យើងមិនមែនជាគ្រីស្ដបរិស័ទលេងៗ តែយើងជាគ្រីស្ដបរិស័ទដែលស្រឡាញ់ យើងជាគ្រីស្ដបរិស័ទអស់មួយជីវិតដោយមានចិត្តស្មោះត្រង់។ យើងជាប់ជាមួយព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់នៅជាមួយយើងជានិច្ច ដូច្នេះយើងយកចិត្តទុកដាក់ ត្រៀមខ្លួនដើម្បីស្ដាប់ព្រះបន្ទូល និងទទួលជីវិតអស់កល្បជានិច្ច។ ឲ្យយើងយកចិត្តទុកដាក់ ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាមហាគ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ឲ្យយើងរស់នៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាជីវិតផ្ទាល់របស់ព្រះជាម្ចាស់។ អាម៉ែន៕